ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

## ប្រមុខការទូតកម្ពុជា៖ សន្តិភាព ស្ថេរភាព និងការអភិវឌ្ឍ ជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ហើយជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន សម្រាប់ការលើកស្ទួយសិទ្ធិមនុស្ស

******

នៅក្នុងជំនួបពិភាក្សាការងារ នៅព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងលោកស្រី **រ៉ូណា ស្មីត** ( Rhona Smith ) អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីអំពីសិទ្ធិមនុស្សនៅកម្ពុជា បានវាយតំលៃខ្ពស់ចំពោះលទ្ធផលនៃជំនួបពិភាក្សាការងាររវាង**លោកស្រី** ជាមួយថ្នាក់ដឹកនាំនិងស្ថាប័នជាច្រើនរបស់កម្ពុជា នៅលើបញ្ហាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងបានស្របទស្សនៈគ្នាលើភាពចាំបាច់ក្នុងការរក្សាជំនួបពិភាក្សាបែបនេះ ដើម្បីបង្កើនការយល់ដឹងពីគ្នាទៅវិញទៅមក ហើយនិងបង្កើនកិច្ចសហប្រតិបត្តិការរវាង**លោកស្រី** ជាមួយរាជរដ្ឋាភិបាលកម្ពុជា។

លោកស្រី **រ៉ូណា ស្មីត** ក៏បានគូសបញ្ជាក់ថាជំនួបពិភាក្សាដ៏ច្រើននេះ ដែលបានប្រព្រឹត្តទៅក្នុងបរិយាកាសស្ថាបនា បានបង្ហាញឲ្យឃើញបន្ថែមទៀតពីការរីកចម្រើនជាច្រើនពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ទន្ទឹមនឹងនោះក៏មានការពិភាក្សាផ្លាស់ប្តូរយោបល់គ្នាលើបញ្ហាការប្រឈមនានាដែលនៅមាន ហើយ**លោកស្រី**បានអះអាងអំពីការត្រៀមខ្លួនបន្តធ្វើការងារ និងកិច្ចសហការជាមួយរាជរដ្ឋាភិបាលដើម្បីដម្នះពុះពារនូវរាល់ការប្រឈមទាំងអស់នោះ។

នៅក្នុងជំនួបពិភាក្សា **ឯកឧត្តមទេសរដ្ឋមន្ត្រី** និងលោកស្រី **រ៉ូណា ស្មីត** មានទស្សនៈឯកភាពគ្នា អំពីសារៈសំខាន់នៃសន្តិភាព ស្ថេរភាពនិងការអភិវឌ្ឍ និងសិទ្ធិមនុស្ស ដែលជាសសរស្តម្ភបីនៃសង្គមដ៏សុខសាន្ត។ ទន្ទឹមនឹងនោះ លោកស្រីបានគូសបញ្ជាក់ពីជំហររបស់លោកស្រីក្នុងឋានៈជាអ្នកការពារសិទ្ធិមនុស្សចាត់ទុកសិទ្ធិមនុស្សជាអាទិភាពទីមួយ។ ជាការឆ្លើយតប **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ថា "សន្តិភាព ស្ថេរភាព និងការអភិវឌ្ឍ ជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ហើយជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ការលើកស្ទួយសិទ្ធិមនុស្ស។" **ឯកឧត្តម** បានលើកឡើងផងដែរអំពីសភាពការណ៍ស្ងប់ស្ងាត់ល្អនៅកម្ពុជាបន្ទាប់ពីមានការសម្រេចរបស់តុលាការកំពូលរំលាយគណបក្សសង្គ្រោះជាតិ ដែលបានបង្ហាញឲ្យឃើញច្បាស់ថាប្រជាជនកម្ពុជាយល់ និងទទួលយកនូវចំណាត់ការរបស់រាជរដ្ឋាភិបាលកន្លងមក តបនឹងការប៉ុនប៉ងជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ហើយអ្វីដែលប្រជាជនចង់បានគឺសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍ ពុំមែនការផ្លាស់ប្តូររបបតាមរយៈការធ្វើបដិវត្តព័ណ៌នោះទេ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីភាពចាំបាច់នៃការគោរពឯករាជ្យ និងអធិបតេយ្យភាពរបស់កម្ពុជា រួមទាំងអធិបតេយ្យភាពរបស់ស្ថាប័ននីតិបញ្ញត្តិ និងរបស់តុលាការផងដែរ។ **ឯកឧត្តម**ក៏បានលើកឡើងពីការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំការបោះឆ្នោតជាតិនាពេលខាងមុខ ដោយមានរបៀបរៀបរយ សេរី យុត្តិធម៌ និងតម្លាភាព។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** និងលោកស្រី **រ៉ូណា ស្មីត** ក៏បានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាលើទិដ្ឋភាពជាច្រើនដែលពាក់ព័ន្ធបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា ដោយបានឯកភាពគ្នាលើចំណុចមួយចំនួន និងបានកត់សម្គាល់ថាមានចំនុចមួយចំនួនដែលមានការយល់ខុសគ្នាចាំបាច់ត្រូវធ្វើការពិភាក្សាបន្តទៀត។ **លោកស្រី** បានសម្តែងការស្វាគមន៍ចំពោះការរីកចម្រើនក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល អប់រំ វប្បធម៌ ដែលបានរួមចំណែកដ៏សំខាន់ក្នុងការលើកស្ទួយសិទ្ធិនានារបស់ប្រជាជន ហើយបានលើកសំណូមពរឲ្យមានការកែលំអលើបញ្ហាមួយចំនួន។ លោកស្រី **រ៉ូណា ស្មីត** បានជំរាប**ឯកឧត្តមទេសរដ្ឋមន្ត្រី** ថាលោកស្រីនឹងយកចិត្តទុកដាក់សហការ និងសម្របសម្រួលជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំរបាយការណ៍របស់លោកស្រីស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់បន្ថែមអំពីសុឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបន្តកិច្ចសហប្រតិបត្តិការជាមួយឧត្តមស្នងការអ.ស.បផ្នែកសិទ្ធិមនុស្ស ដែលបានបង្ហាញឲ្យឃើញតាមរយៈការឯកភាពបន្តអាណត្តិរបស់អ្នករាយការណ៍ពិសេសអ.ស.បផ្នែកសិទ្ធិមនុស្សនៅកម្ពុជា និងការចុះហត្ថលេខាលើអនុស្សរណៈបន្តអាណត្តិរបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៅកម្ពុជា ក៏ដូចជានៅក្នុងការទទួលជួបលោកស្រី ពីសំណាក់ឥស្សរជនជាន់ខ្ពស់ជាច្រើនរបស់កម្ពុជា នាដំណើរទស្សនកិច្ចរបស់លោកស្រីលើកនេះ។

ការពិភាក្សា បានប្រព្រឹត្តទៅក្នុងបរិយាកាសត្រង់ទៅត្រង់មក និងមានការគោរពគ្នាទៅវិញទៅមក។

ថ្ងៃព្រហស្បតិ៍ ១៤ រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១<br>ភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៨